# របាយការណ៍សរុប ការបិទវគ្គអប់រំយុវជនខ្មែរ

សូមក្រាបថ្វាយបង្គំព្រះតេជគុណ................និងព្រះថេរានុថេរៈគ្រប់ព្រះអង្គ !

សូមចំរើនពរលោក....................លោកគ្រូ–អ្នកគ្រូ ព្រមទាំងប្អូនៗ សិស្សានុសិស្ស ទាំងអស់ជាទីរាប់អាន !

ថ្ងៃនេះជាថ្ងៃទី១០ នឹងជាថ្ងៃចុងក្រោយបង្អស់ដែលគំរោងការធម្មចារិកនឹងត្រូវបានបញ្ចប់ នឹងលាប្អូនៗ សិស្សានុសិស្សទាំងអស់ទាំងក្តីអាលោះអាល័យក្រៃពន់ពេកប្រមាណ។ ១០ ថ្ងៃកន្លងផុតទៅដែលយើងបានជួបមុខគ្នា បានភ្លក់រសជាតិនូវម្ហូបអាហារដ៏មានឱជារសរួមគ្នា រសដ៏ចំឡែកនេះគឺរសព្រះធម៌ ដែលជារសឈ្នះអស់រសទាំងពួង ដូចពុទ្ធភាសិតដែលថា “ *សព្វរសំ ធម្មរសោ ជិនាតិ* ” ។ ព្រះធម៌គឺជាសច្ចធម៌ពិតរបស់ជីវិត ដែលត្រូវបានប្រកាសឡើងដោយព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដើម្បីអោយសត្វលោកយើងទាំងអស់នេះ បានសិក្សានិងបដិបត្តិដើម្បីបាននូវប្រយោជន៍ បាននូវសេចក្តីសុខ ដែលប្រយោជន៍និងសេចក្តីសុខនេះ រាប់បញ្ចូលទាំងប្រយោជន៍និងសេចក្តីសុខផ្ទាល់ខ្លួនឯងផង ប្រយោជន៍និងសេចក្តីសុខអ្នកដ៏ទៃផង និងប្រយោជន៍និងសេចក្តីសុខទាំងខ្លួនឯងនិងអ្នកដ៏ទៃផង។ព្រះពុទ្ធសាសនាមានអាយុ ២៥៤៧ ឆ្នាំកន្លងផុតទៅក៏ពិតមែន តែព្រះធម៌របស់ព្រះពុទ្ធនៅតែទាន់សម័យ មានលក្ខណៈជាវិទ្យាសាស្រ្ត មានលក្ខណៈជាគតិបណ្ឌិតនិយមសំរាប់បុគ្គលអ្នកមានសតិបញ្ញានិងស្រលាញ់នូវការសិក្សារៀនសូត្រ។ ព្រះធម៌របស់ព្រះពុទ្ធអង្គនោះមានច្រើនអនេកណាស់ តែយើងមិនអាចយកមកសិក្សាអោយចប់សព្វគ្រប់ក្នុងរយៈពេលតែ១០ថ្ងៃនេះបានទេ ! ដូច្នេះ អាត្មាភាពព្រមទាំងគ្រូដែលជាព្រះភិក្ខុសង្ឃទាំងអស់ជ្រើសសំរាំងយកធម៌ណាដែលប្អូនៗសិស្សានុសិស្សទាំងអស់ ងាយយល់និងងាយយកទៅបដិបត្តិបានក្នុងជីវិតប្រចាំថ្ងៃ ដើម្បីជាប្រយោជន៍និងសេចក្តីសុខទាំងខ្លួនយើងផងនិងអ្នកដ៏ទៃផង ។

តើព្រះធម៌ ឬធម្មនុញ្ញជីវិតដែលយើងបានរៀនទាំង ១០ ថ្ងៃនោះមានអ្វីខ្លះ ?

សូមសរុបដោយសង្ខេប ដើម្បីអោយយើងទាំងអស់គ្នាយល់អោយបានកាន់តែច្បាស់បន្ថែមទៀតគឺ

ទី១ យើងបាននាំគ្នារក្សាសីល ៥ សមាទានសីល៥ ដែលសីល៥នេះ ជាធម៌សាមញ្ញបំផុតសំរាប់មនុស្សលោកទាំងអស់ក្នុងសកលលោកយើងនេះ។ សីលប្រែថាប្រក្រតី ប្រែថាធម្មតា។ ប្រក្រតីរបស់សត្វគឺមានតែអភន្តរញាណ តែប្រក្រតីរបស់មនុស្សគឺមានសីល៥នេះឯង។ សីល៥ មានទាំងធម៌ដែលហាមមិនអោយយើងប្រព្រឹត្ត និងធម៌ដែលជំរុញអោយយើងបដិបត្តិ ជាគូៗនឹងគ្នា គឺ

- កើតជាមនុស្សយើងមិនគួរសំលាប់សត្វ បៀតបៀនអ្នកដ៏ទៃ ប្រទុស្តរាយអ្នកដ៏ទៃ ព្រមទាំងប្រមាទមើលងាយដល់អាយុជីវិតរបស់អ្នកដ៏ទៃជាដើម ដោយអោយមនុស្សយើងម្នាក់ៗត្រូវចេះស្រលាញ់គ្នា មានមេត្តាករុណារាប់អានគ្នាទៅវិញទៅមក មានមេត្តាចំពោះសត្វ និងបរិស្ថាន ។
- កើតមកជាមនុស្សយើងមិនគួរលួចប្លន់ទ្រព្យសម្បត្តិអ្នកដ៏ទៃ កិបកេងប្រវ័ញ្ច និងរកស៊ីខុសច្បាប់ឡើយ យើងគួរតែប្រកបមុខរបរត្រឹមត្រូវ មានសម្មាអាជីវៈ ។
- កើតមកជាមនុស្ស យើងមិនគួរប្រព្រឹត្តខុសផ្លូវភេទ គឺនិយមចូលចិត្តអាសាស្មន់ប្រពន្ធកូនអ្នកដ៏ទៃ ក្បត់ចិត្តប្រពន្ធ ក្បត់ចិត្តប្តី ជាហេតុដែលនាំមេរោគអាក្រក់ជាក់ដល់គ្រួសារខ្លួនយើងគួរតែមានចិត្តស្មោះស្ម័គ្រចំពោះគូស្វាមីភរិយា និងត្រូវចេះសង្រួមក្នុងកាមជានិច្ច។
- កើតមកជាមនុស្ស យើងគួរតែមិនចេះនិយាយកុហក និយាយពាក្យញុះញង់អោយគេបែកបាក់គ្នា និយាយពាក្យអាលអាភាស និងនិយាយពាក្យរោយរាយឥតប្រយោជន៍ យើងគួរតែនិយាយតែពាក្យដែលជាសុភាសិត និងមានសច្ចធម៌ក្នុងខ្លួន ។
- កើតមកជាមនុស្ស យើងគួរជៀសវាងផឹកនូវទឹកស្រវឹង ឬសេពគ្រឿងញៀន ដែលជាហេតុធ្វើអោយយើងវង្វេងវង្វាន់ មិនស្គាល់ខុសស្គាល់ត្រូវ យើងត្រូវតែមានសតិជាប្រចាំ។

ទី២ យើងបានរៀនអំពីលក្ខណៈមនុស្សល្អ៥យ៉ាង តាមទ្រឹស្តីព្រះពុទ្ធសាសនា និងសមស្របតាមច្បាប់ទំនៀមទំលាប់របស់ខ្មែរយើង តើមនុស្សល្អ៥យ៉ាងនោះមានអ្វីខ្លះ?

- ជាកូនដ៏ល្អរបស់មាតាបិតា គោរពបូជាលោកប្រដូចជាព្រះសសរកន្លោងរបស់ខ្លួន
- ជាសិស្សដ៏ល្អរបស់លោកគ្រូ–អ្នកគ្រូ តាំងចិត្តព្យាយាមសិក្សារៀនសូត្រ ត្រងត្រាប់ស្តាប់ពាក្យទូន្មានប្រៀនប្រដៅរបស់លោកគ្រូ–អ្នកគ្រូ ដែលចាត់ទុកជាឪពុកម្តាយទី២របស់យើង។
- ជាមិត្តភក្តិដ៏ល្អរបស់មិត្តភក្តិ គឺត្រូវជាមិត្តដែលស្មោះត្រង់ រួមសុខរួមទុក្ខ និងអាចលះបង់សេចក្តីសុខផ្ទាល់ខ្លួនបានដើម្បីមិត្ត ។
- ជាសមាជិកដ៏ល្អរបស់សង្គម គឺក្នុងសង្គមមួយៗរមែងមានច្បាប់ទំលាប់ ដែលជាច្បាប់របស់រដ្ឋ មានច្បាប់រដ្ឋធម្មនុញ្ញជាដើម ដែលយើងម្នាក់ៗត្រូវតែគោរពតាមអោយបានត្រឹមត្រូវនិងខ្ជាប់ខ្ជួនជានិច្ច ។

- ជាពុទ្ធសាសនិកជនដ៏ល្អរបស់ព្រះពុទ្ធសាសនា ក្នុងឋានៈយើងជាអ្នកកាន់ព្រះពុទ្ធសាសនា ត្រូវតែសិក្សារៀនសូត្រតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ យ៉ាងហោចណាស់ យើងជាពុទ្ធសាសនិកជន ត្រូវស្គាល់អោយច្បាស់អំពីព្រះរតនត្រ័យ ។

ជាចុងក្រោយនេះ ខ្ញុំព្រះករុណាអាត្មាភាពក្នុងនាមអ្នកមើលការខុសត្រូវ ចាត់អប់រំយុវជនតាមគំរោងការធម្មចារិកនៅពេលនេះ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សកលវិទ្យាល័យមហាចុឡាលុងកនរាជវិទ្យាល័យ ឯកឧត្តមសៀង ណាំ ឯកឧត្តមអ៊ុង អឿន និងអ្នកទាំងឡាយដែលមានចំណែកចូលរួមឧបត្ថម្ភនៅពេលនេះ ជាពិសេសសូមថ្លែងអំណរគុណចំពោះព្រះតេជគុណព្រះថេរានុថេរៈគ្រប់ព្រះអង្គ លោកគ្រូនាយកសាលា-នាយកសាលារង លោកគ្រូ-អ្នកគ្រូទាំងអស់ ព្រមទាំងប្អូនៗដែលជាសិស្សានុសិស្ស និងភ្ញៀវកិត្តិយសទាំងអស់ដែលមានវត្តមាននៅទីនេះនឹងដែលបានរួមចំណែកសហការយ៉ាងជិតស្និទ្ធជំរុញអោយគំរោងការធម្មចារិកប្រព្រឹត្តទៅបានយ៉ាងជោគជ័យនិងសំរេចជាស្ថាពរមកដល់ថ្ងៃនេះ ។

ខ្ញុំព្រះករុណាខ្ញុំបាទ សូមលើកដៃបួងសួងដល់គុណព្រះរតនត្រ័យទាំងបីគឺគុណព្រះពុទ្ធគុណព្រះធម៌គុណព្រះសង្ឃ ពុទ្ធរត្នកំចាត់ទុក្ខ ធម្មរត្នកំចាត់ភ័យ សង្ឃរត្នកំចាត់រោគ សេចក្តីសោកហ្មងសៅទាំងពួងជាអនេក ក៏ចូរអោយវិនាសបាត់ទៅ សូមអោយអ្នកទាំងអស់គ្នាបានជួបប្រទះតែសេចក្តីសុខ សេចក្តីចំរើនមានសុខមាលភាពល្អបរិបូរ មានអាយុយឺនយូរ និងមានប្រាជ្ញាភ្លឺស្វាងប្រលងបានពិន្ទុល្អ ជាប់លេខមួយ គ្រប់ពេលវេលាកុំបីអាក់ខានឡើយ ។

សូមអរគុណ !